## ជ័យលាភីលេខ១ ផ្នែកតែងនិពន្ធ

## «ពានរង្វាន់សម្តេចតេជោ ហ៊ុន សែន»

### អបអរសាទរ ទិវាជាតិអំណានលើកទី៣ ១១ មីនា ២០១៨


**យុវជន សោ គឹមស្រួយ**

*ជាសិស្សថ្នាក់ទី ១២ នៃវិទ្យាល័យសម្តេចឳ ខេត្តតាកែវ*


### ចំណងជើងកំណាព្យ៖ កំណប់វិជ្ជានាសួនអំណាន

(កំណាព្យបទ កាកគតិ)

១- ពពួកភូមរា ក្រេបលម្អងផ្កា បំពេញក្បាលទឹក
វីសួនបុប្ផា រីកផ្កាសន្ធឹក ដោយថៃល្ងាចព្រឹក
ស្រោចទឹកចេញផ្កា ។

២- ឯមនុស្សគ្រប់ប្រាណ ភ្លឺថ្លាថ្កើងថ្កាន បានរីកប្រាជ្ញា
ដោយសារការអាន អំណានសិក្សា គម្ពីរសាស្ត្រា
តម្រាក្បួនច្បាប់ ។

៣- ចេះចាំអក្ខរា ពាក្យពេចន៍ភាសា វោហារសាសព្ទ
និពន្ធតាក់តែង ចារចែងចំណាប់ ជំនាញអានស្តាប់
ចាប់យល់អត្ថន័យ ។

៤- អានច្រើនចេះច្រើន បញ្ញាកើតកើន ចម្រើនប្រពៃ
យល់ពីបញ្ហា ប្រាជ្ញាវាងវៃ ដោះស្រាយលកលៃ
ជោគជ័យកិច្ចការ ។

៥- ចេះរៀបចាត់ចែង គ្រប់គ្រងតំណែង ស្វែងពីបញ្ញា
ចេះច្បាប់សង្គម គំនិតថ្លៃថ្លា កសាងវជ្ជា
យល់ការគ្រប់គ្នា ។

៦- អានរួមចំណែក យល់ដឹងគ្រប់ផ្នែក បច្ចេកវិទ្យា
វិជ្ជាជីវៈ ទាក់ទងការងារ មេរៀននានា
វិជ្ជាថ្លាថ្លៃ ។

៧- អានគ្រប់កន្លែង តាមផ្ទះសម្បែង ជាក់ស្តែងរាល់ថ្ងៃ
អាននៅសាលា ក្នុងបណ្ណាល័យ សៀវភៅនៅដៃ
និស្ស័យអំណាន ។

៨- ឯកសារនានា ស្រឡាញ់គាំពារ គ្រប់គ្នារៀនអាន
ទើបបែកប្រាជ្ញា ដូចផ្ការីកថ្កាន ក្នុងសួនអំណាន
បានផ្កាវិជ្ជា ។

៩- កូនខ្មែរគ្រប់ប្រាណ ផ្សព្វផ្សាយការអាន ឱ្យបានគ្រប់គ្នា
គាំទ្រលើកស្ទួយ ជប់មួយមិនា អានទាំងអស់គ្នា
ទិវាអំណាន ។

## ជ័យលាភីលេខ២ ផ្នែកតែងនិពន្ធ

## «ពានរង្វាន់សម្តេចតេជោ ហ៊ុន សែន»

### អបអរសាទរ ទិវាជាតិអំណានលើកទី៣ ១១ មីនា ២០១៨


**យុវតី ចែម ស្រីពេជ្រ**

*ជាសិស្សថ្នាក់ទី ១១ នៃវិទ្យាល័យ ប៊ុន រ៉ានី ហ៊ុនសែន ចរិយាវង្ស ខេត្តកែប*


**ចំណងជើងកំណាព្យ៖ វិជ្ជាជាទ្រព្យដ៏ប្រសើរ**

(កំណាព្យបទ ពាក្យប្រាំពីរ)

១- ពណ៌មាសចែងចាំងចរចេញជះ ជាតិខ្មែរខ្ពស់រះសមស្ដឹមស្ដែ
រុងរឿងថ្កើងថ្កានគ្រប់វិស័យ លម្អឆ្លាក់ច្នៃថ្លៃវិចិត្រ ។

២- ឈាមជ័រជាខ្មែរថែក្បួនច្បាប់ ចំណេះចំណាប់យ៉ាងប្រណីត
អំនានសក្ដិសមស្ដម្ភផ្ទង់ផ្ចិត តាមក្រមតាមក្រឹត្យខិតសិក្សា ។

៣- ខំរៀនខំអានបានជោគជ័យ បញ្ចេញអត្ថន័យបានសុខា
ឈរមានកិត្តិយសស្រស់សង្ហា ចម្រើនកិច្ចការថ្លាគំនិត ។

៤- អានច្រើនចេះច្រើនចម្រើនដឹង គ្មានអ្វីរាស់ថ្លឹងឧត្តមពិត
ខំប្រឹងស្ដាប់សួរស្រាវជ្រាវគិត ផ្ចិតផ្ចង់លម្អិតពិតបានល្អ ។

៥- អំណានជាទ្រព្យមហាសាល បណ្ដុះបណ្ដាលថ្នាលបវរ
ដូចចម្លាក់បដិមាករ ដាប់ឆ្លាក់លាបពណ៌សលឿងខ្មៅ ។

៦- ការអាននាំមនុស្សផុតអស់ព្រួយ ធ្វើជាជំនួយជួយបាត់ខ្លៅ
ពង្រឹងចំណេះចេះមិនឆៅ វិថីទិសដៅប្រៀបសួគ៌ា។

៧- ហេតុនេះអំណានបានរំលេច ចែងចាំងដូចពេជ្រស្រស់សោភា
ពន្លឺពណ្ណរាយដូចចន្ទ្រា ដល់ឋានរមនាល្អក្រៃក្រាស់។

៨- ជីវិតមនុស្សទាំងសកល អំណានបានផ្ដល់គ្រឹះមូលដ្ឋាន
អានបានចំណេះចេះចំណាន អប់រំឱ្យថ្កានមូលដ្ឋានប្រាំ៕

# ជ័យលាភីលេខ៣ ផ្នែកតែងនិពន្ធ

# «ពានរង្វាន់សម្តេចតេជោ ហ៊ុន សែន»

## អបអរសាទរ ទិវាជាតិអំណានលើកទី៣ ១១ មីនា ២០១៨

**យុវជន យ៉ឹន ឈុងអ៊ុយ**

*ជាសិស្សថ្នាក់ទី ១២ នៃវិទ្យាល័យពញាក្រែក ខេត្តត្បូងឃ្មុំ*

## ចំណងជើងកំណាព្យ៖ អំណានជាទ្រព្យដ៏ប្រសើរ

(កំណាព្យបទ ពាក្យប្រាំពីរ)

១- វិជ្ជាជាទ្រព្យគាប់ចិន្តា ប្រសើរថ្លៃថ្លាពេកកន្លង
កេរ្តិ៍ឈ្មោះល្បាញល្បីខ្ពស់ត្រសង ល្អដូចលម្អងលាស់ពីផ្កា ។

២- វិជ្ជាច្បាស់ពិតកើតចេញពី ការចេះសំកីខំឧស្សាហ៍
ខំប្រឹងរៀនអានក្នុងសាលា ប្រឹងស្វ័យសិក្សាឱ្យតម្លៃ ។

៣- នៅពេលដែលយើងប្រឹងប្រែងខំ រួមទាំងអារម្មណ៍ចេះកែខៃ
លៃលកពេលរៀនយកស្នាដៃ ពិតជាជោគជ័យយ៉ាងថ្លៃថ្លា ។

៤- កាលណាដែលយើងមានចំណេះ យើងត្រូវតែចេះថែរក្សា
ប្រឹងប្រែងជួយជាតិសព្វកិច្ចការ គោរពសាសនាដោយឃ្មាតខ្មី ។

៥- វប្បធម៌ជាតិឃ្លាតពុំបាន កូនចៅគ្រប់ប្រាណត្រូវបេតី
ខ្ជាប់ខ្ជួនឱ្យបានកូនប្រុសស្រី រក្សាកុំបីរំលងឡើយ ។

៦- ប្រទេសចម្រើនពិតបានល្អ រួមគ្នាបន្តកុំកន្តើយ
ត្រូវនាំខ្លួនឯងឱ្យដល់ត្រើយ ប្រាណបានធូរស្បើយព្រោះសិក្សា ។

៧- ជាតិខ្ពស់ព្រោះមានធនជានមនុស្ស ត្រូវចេះទម្លុះរាល់បញ្ហា
ប្រឹងប្រែងឱ្យបានមានប្រាជ្ញា ទើបជាតិថ្លៃថ្លាបានសុខអើយ ៕